**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ចាន់ ក្មកឮ** ប្រធានសាខាក្រុមហ៊ុនប្រេងឥន្ធនៈ **TOTAL** ខេត្តកំពត ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងលូ ក្នុងទីរួមខេត្តកំពត ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៤១.០០០.០០០ រៀល ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៦៧.៩៧.៣...អនក្រ.បក -

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
៣៧
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១៖** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ចាន់ គុគលន់** សប្បុរសជន នៅ ខេត្តកំពង់ធំ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា នៅ *វិទ្យាល័យ ជា ស៊ីម ប្រឡាយ* ស្ថិតនៅ ឃុំប្រឡាយ ស្រុកស្ទោង និងសាងសង់ស្ពានអូរក្រូច ស្ថិតក្នុងស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ចំណាយអស់ថវិកាសរុបចំនួន ១២.០០០ ដុល្លារអាមេរិក ។

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញៈ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ២៣៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ-បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **សុខ ស៊ីឡុ** វរមន្ត្រី ថ្នាក់លេខ ៩ ជា**ប្រធាននាយកដ្ឋានរដ្ឋបាល** នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនសពលោក **Che Shin YOO** អតីតទីប្រឹក្សាបច្ចេកទេសក្រុមហ៊ុន **KCI ( Korea Consultants International )** ដែលមានស្នាដៃល្អក្នុងការជួយស្ថាបនា ដំណាក់កាលដំបូង នៃកំណាត់ផ្លូវជាតិ លេខ ៥-៦ ( ប៉ោយប៉ែត-សៀមរាប ) និង ផ្លូវលេខ ៥៦-៦៨ ( ស៊ីសូផុន-សំរោង-ក្រឡាញ់ ) រហូតដល់ធ្លាក់ខ្លួនឈឺជាទម្ងន់ នៅនឹងការដ្ឋានផ្ទាល់ និងបានទទួលមរណភាពនៅមន្ទីរពេទ្យ ក្រុងសេអ៊ូល កាលពីថ្ងៃទី២៥ ខែ មករា កន្លងទៅ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...២៧៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឡាយ ឆ្លុក** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៥១៤ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៥១៥ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង

-បានឃើញសេចក្តីសំរេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម

-យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាមដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម ប្រធាន

២-ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៣-ឯកឧត្តម **ម៉ុន សម** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤-ឯកឧត្តម **ហួន សាវ៉ាង** អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៥-ឧត្តមសេនីយ៍ឯក **ឈុំ សុជាត** នាយរងសេនាធិការ និងជានាយកទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ សមាជិក

៦-ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧-លោកជំទាវ **ក្ងួយ ពិសី** លេខាធិការ នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨-ឯកឧត្តម **ម៉ុន ហ៊ាន** អគ្គនាយកកិច្ចការបច្ចេកទេស និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ឡាវ និងថៃ ក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៩-ឧត្តមសេនីយ៍ឯក**ចាន់ អ៊ាន** ប្រធាននាយកដ្ឋានកណ្តាល ក្រសួងមហាផ្ទៃ សមាជិក

១០-ឧត្តមសេនីយ៍ឯក**ទេព ចំរើន**ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងការពារជាតិ សមាជិក

១១-ឯកឧត្តម **អភិបាលខេត្ត** កំពង់ចាម សមាជិក

១២-ឯកឧត្តម **អភិបាលខេត្ត** ស្វាយរៀង សមាជិក

១៣-ឯកឧត្តម **អភិបាលខេត្ត** ព្រៃវែង សមាជិក

១៤-ឯកឧត្តម **អភិបាលខេត្ត** កណ្តាល សមាជិក

| | | |
|---|---|---|
| ១៥-ឯកឧត្តម **អភិបាលខេត្ត** | តាកែវ | សមាជិក |
| ១៦-ឯកឧត្តម **អភិបាលខេត្ត** | កំពត | សមាជិក |
| ១៧-ឯកឧត្តម **អភិបាលខេត្ត** | ក្រចេះ | សមាជិក |
| ១៨-ឯកឧត្តម **អភិបាលខេត្ត** | មណ្ឌលគិរី | សមាជិក |
| ១៩-ឯកឧត្តម **អភិបាលខេត្ត** | រតនគិរី | សមាជិក |
| ២០-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ១ | សមាជិក |
| ២១-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ២ | សមាជិក |
| ២២-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ៣ | សមាជិក |
| ២៣-ឧត្តមសេនីយ៍ទោ **សេង សារី** | នាយសេនាធិការ និងជានាយការិយាល័យការពារព្រំដែនកងទ័ពជើងគោក ក្រសួងការពារជាតិ | សមាជិក |
| ២៤-លោក **អ៊ិត សុត្ថា** | ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៥-លោក **ឡាយ ទោហារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ | សមាជិក |
| ២៦-ឧត្តមសេនីយ៍ត្រី **ពេជ្រ ជ័ច័ន្ទ** | ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ | សមាជិក |
| ២៧-លោក **ហួ ពេជ្រមោលី** | អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ប្រការ២** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម អាចបង្កើតអនុគណៈកម្មការបច្ចេកទេសចំរុះ ក្រុមប្រតិបត្តិការចំរុះ និងក្រុមបច្ចេកទេសចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក សំរាប់ធ្វើជាសេនាធិការ ។

**ប្រការ៣** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម មានភារកិច្ចដូចតទៅ :

-អនុវត្តឱ្យបានសំរេចជាស្ថាពរនូវសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និង

សាធារណរដ្ឋសង្គមនិយមវៀតណាម

-រៀបចំចាត់ចែងបែបបទផ្លូវច្បាប់និងបច្ចេកទេសសំរាប់ការងារខ័ណ្ឌសីមានិងបោះបង្គោលព្រំដែន

-រៀបចំចាត់ចែងតួនាទី ភារកិច្ច និងសមាសភាពរបស់អនុគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែន ក្រុមប្រតិបត្តិការចំរុះ និងក្រុមបច្ចេកទេសចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង

-ធ្វើការត្រួតពិនិត្យ ដោះស្រាយបញ្ហា និងឯកសារនានា ដែលក្រុមប្រតិបត្តិការ និង ក្រុមបច្ចេកទេសវាស់វែងជួបប្រទះ លើដីជាក់ស្តែង

-ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់រាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

**ប្រការ៤** : គ្រប់សមាជិកនៃគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ៥** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី នឹងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៦** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក នឹងត្រូវរំសាយទៅវិញនៅពេលណាដែលការងារអនុវត្តសន្ធិសញ្ញាដូចក្នុងប្រការ៣ ត្រូវបានចប់សព្វគ្រប់ ។

**ប្រការ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័ន អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៧

-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ: ២៨១.........ប្រក.សហវ.បទ.ច.ម.៣

# ប្រកាសអន្តរក្រសួង
# ស្តីពី
# អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍។

- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។
- បានឃើញលិខិតលេខ ១១៥ស.ហ.វ.ម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។
- បានឃើញសារាចរណែនាំលេខ ០០២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីវិជ្ជទេយ្យចំណូល ។
- បានឃើញការងារចាំបាច់របស់នាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និងទំនាក់ទំនងអន្តរជាតិ ។
- យោងកំណត់ហេតុអង្គប្រជុំអន្តរក្រសួង ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៥ ។

## ស ម្រេ ច

**ប្រការ ១ :** ប្រកាសនេះមានគោលដៅគ្រប់គ្រង និងផ្តល់អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ជូនផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ ។

**ប្រការ ២ :** - អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ គឺជាអាជ្ញាប័ណ្ណដែលត្រូវផ្តល់ជូនផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ បន្ថែមលើសេវាប្រៃសណីយ៍ ដែលស្ថិតក្រោមអាជីវកម្មរបស់រដ្ឋ ដើម្បីជួយបំពេញនិងទ្រទ្រង់សេវាប្រៃសណីយ៍ និងបំរើតាមសំណូមពររបស់ប្រជាពលរដ្ឋ ។

- សេវាបញ្ញើឆាប់រហ័សអន្តរជាតិ គឺជាសេវាកម្មប្រៃសណីយ៍ទំនើបមួយដែលបានរៀបចំប្រព័ន្ធសេវាមានលក្ខណៈអន្តរជាតិ។ សេវានេះត្រូវបានធានានូវសុវត្ថិភាពចាប់តាំងពី ទទួល បញ្ជូន និងចែកដល់ដៃអ្នកទទួល មានការតាមដានជាប្រចាំ ដោយការកត់ត្រាតាមប្រព័ន្ធព័តិមានវិទ្យុ និងមានអាទិភាពផ្សេងបញ្ញើដទៃទៀត។

**ប្រការ ៣ :** គ្មានផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គលណាមួយ អាចធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដោយគ្មានអាជ្ញាប័ណ្ណ មានសុពលភាពដែលចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ឡើយ ។

**ប្រការ ៤ :** ផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដែលអាចធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិបាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ ឬបរទេស
- មានកាយសម្បទាគ្រប់គ្រាន់
- មានបទពិសោធន៍ខាងវិស័យប្រៃសណីយ៍
- បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- មានទីតាំងសមស្រប និង ច្បាស់លាស់ ត្រូវមានឯកសារបញ្ជាក់

ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗ ត្រូវមានអាសនៈមួយកន្លែង សំរាប់តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាសនៈមួយកន្លែងទៀត សំរាប់តំណាងឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ ៥ :** ផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងចង់ធ្វើអាជីវម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ត្រូវដាក់ពាក្យសុំ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ នៅនាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និង ទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

**ប្រការ ៦:** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីសេចក្តីសំរេចរបស់ក្រសួង ចំពោះការអនុញ្ញាត ឬមិនអនុញ្ញាត ពាក្យសុំក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ ពីថ្ងៃដែលបានទទួលពាក្យសុំ ។

**ប្រការ ៧:** អ្នកកាន់អាជ្ញាប័ណ្ណ មិនអាច ជួល លក់ ឬបញ្ចាំ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ទៅឱ្យអ្នកផ្សេងទៀតបានឡើយ ។ ការបោះបង់ ឬការផ្ទេរ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ទៅឱ្យជនណាផ្សេងទៀត អាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

**ប្រការ ៨:** ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានសិទ្ធិក្នុងការ កែសម្រួល ព្យួរ និង បដិសេធន៍ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ក្នុងករណីដូចខាងក្រោម :

ក- ការកែសម្រួល អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ក្នុងករណី អ្នកកាន់អាជ្ញាប័ណ្ណបានស្នើសុំ :

- ពង្រីកសាខាបន្ថែម
- ប្តូរទីតាំង
- លុបចោលសាខាមួយចំនួន ។

ខ- ការព្យួរអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ក្នុងករណី អ្នកកាន់អាជ្ញាប័ណ្ណ :

- ធ្វើអាជីវកម្មប្រៃសណីយ៍ខុសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ

- ពុំបានបង់ប្រាក់វិភាគទាន ជូននាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមកាលកំណត់ ។
- មិនបានអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួនបីលើក ក្នុងមួយលើកមានរយៈពេល ១៥ថ្ងៃ (ដប់ប្រាំថ្ងៃ) អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍នេះ នឹងត្រូវព្យួរ រហូតដល់អស់សុពលភាព ។
- ត្រូវបានស្ថាប័នមានសមត្ថកិច្ចស្នើសុំឱ្យព្យួរ ដោយមូលហេតុមានការរំលោភ លើច្បាប់ជាធរមាន ។

គ- ការបដិសេធន៍ ឬ ដកហូតអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ក្នុងករណី :

- អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ អស់សុពលភាពហើយពុំបានស្នើសុំបន្ត
- អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ត្រូវបានព្យួរ ២ដង ហើយពុំរាងចាល
- អ្នកកាន់អាជ្ញាប័ណ្ណបាន ជួល លក់ ឬបញ្ចាំ អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ទៅឱ្យអ្នកផ្សេងទៀត ដោយគ្មានការអនុញ្ញាត ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- អ្នកកាន់អាជ្ញាប័ណ្ណពុំបានធ្វើសកម្មភាពរយៈពេល ៦ខែ (ប្រាំមួយខែ) ក្រោយពីទទួលបានអាជ្ញាប័ណ្ណ ។

**ប្រការ ៩:** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវជូនដំណឹងដល់អ្នកកាន់អាជ្ញាប័ណ្ណ ជាលាយលក្ខណ៍អក្សរ និងចុះផ្សាយតាមបណ្តាញព័ត៌មាន នូវសេចក្តីសម្រេចរបស់ក្រសួង ចំពោះការបដិសេធន៍ ឬដកហូតមកវិញនូវអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ។ អ្នកកាន់អាជ្ញាប័ណ្ណ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ២៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងតាមបញ្ញើអនុសិដ្ឋ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ ១០:** អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេលតិចបំផុត២ឆ្នាំ និងច្រើនបំផុត៥ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ ក្នុងករណីបន្តធ្វើអាជីវកម្មអ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ អោយបាន ៣០ថ្ងៃ មុនពេលអាជ្ញាប័ណ្ណអស់សុពលភាព ។

**ប្រការ ១១:** តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ គណនាតាមសុពលភាពនៃអាជ្ញាប័ណ្ណនីមួយៗ ហើយអ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ត្រូវបង់ជាប្រាក់រៀលគិតតាមតម្លៃអាជ្ញាប័ណ្ណជាដុល្លារអាមេរិក ដោយឈរលើមូលដ្ឋានតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃបានបង់ [illegible] តម្លៃអាជ្ញាប័ណ្ណទាំងបួនប្រភេទត្រូវបង់ ៥០០ ដុល្លារអាមេរិក នៅពេលដាក់ពាក្យស្នើសុំ និងបង់បន្ថែម នៅពេលទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

ក- តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេល២ (ពីរ) ឆ្នាំ ត្រូវបានកំណត់ ៥០០០ ដុល្លារអាមេរិក ។

ខ- តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេល៣ (បី) ឆ្នាំ ត្រូវបានកំណត់ ៧.២៥២ ដុល្លារអាមេរិក ។

គ- តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេល៤ (បួន) ឆ្នាំ ត្រូវបានកំណត់ ៩.២៨៤ ដុល្លារអាមេរិក។

ឃ- តម្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ មានសុពលភាពរយៈពេល៥ (ប្រាំ) ឆ្នាំ ត្រូវបានកំណត់ ១១.១២៣ ដុល្លារអាមេរិក ។

- ក្នុងករណីស្នើសុំអាជ្ញាប័ណ្ណ ពុំទទួលបានការអនុញ្ញាត ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់បង់ ដំបូងចំនួន ៥០០ ដុល្លារអាមេរិក ត្រូវប្រគល់ជូនអ្នកស្នើសុំវិញ ។

- ក្នុងករណីអ្នកដាក់ពាក្យបានបោះបង់ចោលការស្នើសុំអាជ្ញាប័ណ្ណ ក្រោយពេលគោលការណ៍ ត្រូវបាន អនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់កក់ចំនួន ៥០០ ដុល្លារអាមេរិក ត្រូវរឹបអូស ជាថវិកាជាតិ ។

ប្រការ ១២: ក្រៅពីការបង់ថ្លៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវមានកាតព្វកិច្ច បង់ប្រាក់ វិភាគទាន ដើម្បីចូលរួមអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ជនបទ និងតំបន់ដាច់ស្រយាល ទៅតាមស្នាក់ការ ឬសាខា ដូចតទៅ :

ក. នៅរាជធានីភ្នំពេញ ត្រូវបង់ ៥.០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ។

ខ. នៅតាមបណ្តាខេត្ត-ក្រុង ណាមួយ ក្នុងចំណោមខេត្ត-ក្រុងទាំង ៦ ដូចជា : ខេត្ត កណ្តាល កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ សៀមរាប និង ក្រុងព្រះសីហនុ ត្រូវបង់ ២.៥០០ដុល្លារអាមេរិក ក្នុងមួយឆ្នាំ។

គ. នៅតាមបណ្តាខេត្ត-ក្រុង ណាមួយ ក្នុងចំណោមខេត្ត-ក្រុងទាំង ១២ ដូចជា : ខេត្ត កំពង់ស្ពឺ តាកែវ កំពត ស្វាយរៀង ព្រៃវែង ក្រចេះ កំពង់ធំ កំពង់ឆ្នាំង ពោធិសាត់ កោះកុង ក្រុងកែប និងក្រុងប៉ៃលិន ត្រូវបង់ ១.៥០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ។

ឃ. នៅតាមបណ្តាខេត្តណាមួយ ក្នុងចំណោមខេត្តទាំង ៥ ដូចជា : ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និង ឧត្តរមានជ័យ ត្រូវបានលើកទឹកចិត្ត ដោយមិនបង់ប្រាក់វិភាគទាន ប្រចាំឆ្នាំទេ។

អ្នកកាន់អាជ្ញាប័ណ្ណ អាចពង្រីកសាខារបស់ខ្លួន មួយ ឬច្រើននៅក្នុងខេត្ត-ក្រុងតែមួយ មិនចាំបាច់ ត្រូវបង់ប្រាក់វិភាគទានបន្ថែមទៀតឡើយ។

ប្រាក់វិភាគទានខាងលើនេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់នៅនាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្នុងខែ មិថុនា រៀងរាល់ឆ្នាំ ។

ប្រការ ១៣: ដើម្បីធានាឱ្យការគ្រប់គ្រង និងការផ្តល់អាជ្ញាប័ណ្ណ ដំណើរការទៅដោយប្រសិទ្ធភាព ប្រាក់ចំណូលដែលបានមកពីថ្លៃអាជ្ញាប័ណ្ណ ចំណូលប្រាក់វិភាគទាន និងការផាកពិន័យ ត្រូវបានបែងចែកដូចខាងក្រោម:

១- ប្រាក់ចំណូលដែលបានមកពីថ្លៃអាជ្ញាប័ណ្ណ ត្រូវបង់ចូលថវិកាជាតិចំនួន ១០០% ក្នុងនោះ ចំនួន ៣០% សំរាប់ឧបត្ថមក្រុមការងារត្រួតពិនិត្យ និងមន្ត្រីពាក់ព័ន្ធ ។

២- ប្រាក់ចំណូលវិភាគទាន ត្រូវបង់ចូលអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួន ១០០% ក្នុងនោះ :

- ចំនួន ៧០% សំរាប់អភិវឌ្ឍន៍វិស័យប្រៃសណីយ៍ជនបទ និងតំបន់ដាច់ស្រយាល ។
- ចំនួន ៣០% សំរាប់ឧបត្ថមក្រុមការងារត្រួតពិនិត្យ និងមន្ត្រីពាក់ព័ន្ធ ។

៣- ប្រាក់ចំណូលពីការផាកពិន័យ ត្រូវបង់ចូលថវិកាជាតិចំនួន ១០០% ក្នុងនោះ ចំនួន ៥០% សំរាប់ឧបត្ថមក្រុមការងារត្រួតពិនិត្យ និង មន្ត្រីពាក់ព័ន្ធ ។

ប្រការ ១៤: អ្នកកាន់អាជ្ញាប័ណ្ណត្រូវបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិក្នុងកិរិតជាក់លាក់ និងត្រឹមត្រូវតាមខ្លឹមសារនៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍នោះតែប៉ុណ្ណោះ ។ ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណចង់ពង្រីកសាខាបន្ថែម ឬ ប្តូរទីតាំង ឬសុំលុបចោលសាខាមួយចំនួនដែលមានចែងក្នុងអាជ្ញាប័ណ្ណ ត្រូវសុំការអនុញ្ញាតជាមុនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ប្រការ ១៥ : អ្នកកាន់អាជ្ញាប័ណ្ណអាចបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដែលមានទម្ងន់ក្រោម៥០០ក្រាមបាន ករណីអ្នកកាន់អាជ្ញាប័ណ្ណនោះគិតតម្លៃសេវាផ្ញើ លើស៥ដង នៃតម្លៃសេវាផ្ញើលិខិតធម្មតារបស់រដ្ឋ ។

ប្រការ ១៦: អ្នកកាន់អាជ្ញាប័ណ្ណ អាចធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិគ្រប់ប្រភេទ លើកលែងតែវត្ថុដែល ត្រូវហាមឃាត់ ដូចមានចែងក្នុងច្បាប់ស្តីពីវិស័យប្រៃសណីយ៍ត្រង់មាត្រា១៩ ។

ប្រការ ១៧: អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុ (Financial Statements) ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀងរាល់ត្រីមាស ឱ្យបានទៀងទាត់ ។ របាយការណ៍នេះត្រូវបានរក្សាការសំងាត់ និងទុកជាឯកសារនៅនាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត្ត និងទំនាក់ទំនងអន្តរជាតិ ។

ប្រការ ១៨: អ្នកកាន់អាជ្ញាប័ណ្ណត្រូវទទួលខុសត្រូវ និងសងចំពោះអ្នកផ្ញើ ឬអ្នកទទួល ក្នុងករណីមានការបាត់បង់ ឬខូចខាត នូវរាល់បញ្ញើឆាប់រហ័សអន្តរជាតិ លើកលែងបញ្ញើត្រូវបានបាត់បង់ ឬខូចខាត ដោយករណីប្រធានស័ក្តិ ឬបញ្ញើដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ត្រូវបានរឹបអូស ។

ប្រការ ១៩ : អ្នកផ្ញើ ឬអ្នកទទួល មានសិទ្ធិប្តឹងតវ៉ាអំពីបញ្ញើឆាប់រហ័សអន្តរជាតិ ដែលបានបាត់បង់ ឬខូចខាត ចំពោះអ្នកកាន់អាជ្ញាប័ណ្ណដែលខ្លួនបានផ្ញើ ឬទទួលក្នុងអំឡុងពេល ០៦ខែ គិតចាប់ពីថ្ងៃផ្ញើ ឬថ្ងៃទទួលបញ្ញើ ។

ប្រការ ២០: នាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចគ្រប់គ្រងអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ និងតាមដាននូវរាល់សកម្មភាពរបស់ក្រុមហ៊ុនធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ឱ្យអនុវត្តត្រឹមត្រូវតាមខ្លឹមសារ នៃអាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍ ដែលបានផ្តល់ជូន ។

ប្រការ ២១: នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនឯកជនធ្វើអាជីវកម្មសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដើម្បីកសាងសំណុំឯកសារ នៅពេលមានវិវាទ ឬការតវ៉ាផ្សេងៗ ។

ប្រការ ២២:- អ្នកកាន់អាជ្ញាប័ណ្ណទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងប្រការ១៦ នៃប្រកាសនេះ ត្រូវទទួលពិន័យ និង/ឬ ផ្តន្ទាទោសតាមមាត្រា៤៦ នៃច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ។

- ត្រូវពិន័យជាប្រាក់ពី១.០០០.០០០រៀល ដល់ ១០.០០០.០០០រៀល អ្នកកាន់អាជ្ញាប័ណ្ណប្រៃសណីយ៍ មិនគោរពតាមប្បញ្ញត្តិ ដូចមានចែងក្នុងប្រការ១៤ នៃប្រកាសនេះ ។ ករណីមិនរាងចាល ត្រូវដកហូតអាជ្ញាប័ណ្ណដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

- ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០រៀល ដល់១០.០០០.០០០រៀល ចំពោះជនណាដែលធ្វើអាជីវកម្មបំរើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដោយគ្មានអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ហើយត្រូវបញ្ឈប់អាជីវកម្មខុសច្បាប់នេះជាបន្ទាន់ ដោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។ ករណីមិនរាងចាលត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

- អ្នកកាន់អាជ្ញាប័ណ្ណប្រៃសណីយ៍ មិនគោរពតាមប្បញ្ញត្តិដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០រៀល ដល់២០.០០០.០០០រៀល ហើយត្រូវដកហូតអាជ្ញាប័ណ្ណ ។

ប្រការ ២៣:រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២៨:** អគ្គនាយកដ្ឋាន នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ស៊ូ-ឃុន

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្តក្រុង

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៨

  "ដើម្បីមុខការ"
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**ក្រសួងយុត្តិធម៌**

លេខ ១៤៥...... ប្រក.កសក.កយ

# ប្រកាសរួម

## ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូសំណុំលិខិត ដោះស្រាយបទល្មើសអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ដល់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខជស/រកម/០៦៩៦/០២ចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការគ្រប់គ្រងឱសថ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និង សេវា

-បានឃើញក្រឹត្យលេខ ២១ ក្រ. ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០២/០០៥ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៦ មាត្រា៣៨ មាត្រា៩០ និង មាត្រា៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ស្តីពីការរៀបចំ និង ការប្រព្រឹត្ត

ទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ស្តីពីសត្តឃាតដ្ឋាន និង កន្លែងពិឃាតសត្វ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

-បានឃើញប្រកាសលេខ ២៧ ប្រក.រប.កយ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីរបៀបរបប ធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌

-បានឃើញប្រកាសលេខ ៥៨៨ ប្រក.កសក.បុ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និង អង្គភាពចំណុះនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

-តាមសំណើរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទលេខ៨៩១១កសក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០៥

## សម្រេច

**ប្រការ១:** ត្រូវបានទទួលស្គាល់ដោយច្បាប់ជាមន្ត្រីនគរបាលយុត្តិធម៌ ឬ អាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ដល់មន្ត្រីរាជការនៃនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង មន្ទីរកសិកម្មខេត្ត ក្រុងរួមមាន :

-ប្រធាន និង អនុប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

-ប្រធាន និង អនុប្រធានមន្ទីរកសិកម្មខេត្ត ក្រុង

-ប្រធាន និង អនុប្រធានការិយាល័យ បសុព្យាបាល

-ប្រធាន និង អនុប្រធានការិយាល័យ សុខភាពសាធារណៈ

-ប្រធាន និង អនុប្រធានការិយាល័យ ផលិតកម្ម

-ប្រធាន និង អនុប្រធានការិយាល័យ នីតិកម្ម និង វិវាទ

-ប្រធាន និង អនុប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវ ផលិតកម្ម និង បសុព្យាបាល

-ប្រធាន និង អនុប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុង

**ប្រការ២:** អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុង ប្រការ១ ប្រើប្រាស់ជាផ្លូវការនូវគំរូលិខិតដោះស្រាយបទល្មើសអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វរួមមាន:

១-កំណត់ហេតុចុះត្រួតពិនិត្យទីកន្លែងកើតហេតុ

២-កំណត់ហេតុនៃបទល្មើស

៣-កំណត់ហេតុបទល្មើសជាក់ស្តែង

៤-កំណត់ហេតុឆែកឆេរ

៥-កំណត់ហេតុសួរចម្លើយជនល្មើស

៦-កំណត់ហេតុសាកសួរបំភ្លឺ

៧-កំណត់ហេតុដកហូត ឃាត់ទុកវត្ថុតាងជាបណ្តោះអាសន្ន

៨-កំណត់ហេតុយកគំរូសំណាកមកវិភាគ

៩-កំណត់ហេតុប្រគល់ និង ទទួលគ្រប់គ្រងវត្ថុតាង

១០-កំណត់ហេតុចាប់ឃាត់ខ្លួនជនល្មើស

១១-កំណត់ហេតុប្រគល់ និង ទទួលជនល្មើស

១២-សលាកប័ត្រទោសទណ្ឌ

១៣-ព្រឹត្តិបត្រព័ត៌មាន

១៤-របាយការណ៍សំយោគ

១៥-ដីកាអម ។

ដូចមានភ្ជាប់មកជាមួយនេះដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ងាយស្រួលបំពេញបែបបទប្រតិបត្តិការរបស់ខ្លួនឱ្យបានសមស្របតាមនីតិវិធីច្បាប់និង លិខិតបទដ្ឋានគតិយុត្ត ដែលនៅជាធរមានបញ្ញត្តិ ។

**ប្រការ៣:** ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌នៃនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និងមន្ទីរកសិកម្ម ខេត្ត ក្រុង ត្រូវស្ថិតនៅក្រោមការដឹកនាំសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធី និងវិធានការស៊ើបអង្កេត ដើម្បីធានាការចោទប្រកាន់ឱ្យមានប្រសិទ្ធភាពដោយស្ថិតក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

**ប្រការ៤:** មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងប្រការ១ អយ្យការអមតុលាការខេត្ត ក្រុង និង គ្រប់តុលាការខេត្ត ក្រុងត្រូវអនុវត្តតាមគំរូសំណុំលិខិតដោះស្រាយបទល្មើស អនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វដូចមានចែងក្នុងប្រការ២ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៥:** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០០៦

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**អង្គ.វង្សវឌ្ឍនះ** **ចាន់.សារុន**

**ចំលងជូន:**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- គ្រប់ក្រសួង ស្ថាប័ន
- អភិបាលខេត្ត ក្រុង
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ដូចប្រការ៤ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៩៣ ពណ.នតក

ភ្នំពេញថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **គ្រេត ហ្វ័រឈូន គ្រុប អ៊ិនធើណេសិនណល លីមីធីត**
**GREAT FORTUNE GROUP INTERNATIONAL LIMITED**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8540/06P ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក ZHAO QIWEN ប្រធានក្រុមប្រឹក្សាភិបាល
លោក **ឆយ យូ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១២ វិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-អភិវឌ្ឍន៍ដីធ្លី
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-ពិសេសទិញលក់ សំភារៈសំណង់គ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់ផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវា[illegible]ក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យកសិ-ឧស្សាហកម្ម : ដាំដំណាំកៅស៊ូ កែច្នៃជ័រកៅស៊ូ និងដើមកៅស៊ូ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម-កាត់ដេរ-ប៉ាក់សំលៀកបំពាក់

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
អគ្គនាយកជិការ

ឌឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៩៤ ពណ.នគក

ភ្នំពេញថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **(ខេមបូឌា ) យេផេន អ៊ិនវេសមេន**

**( CAMBODIA ) JAPAN INVESTMENT Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8526/06P ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក MAKOTO ISHIHARA ប្រធានក្រុមប្រឹក្សាភិបាល

លោក **ឆាន ច័ន្ទរ៉េង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ១៦ ផ្លូវលេខ៣១០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទូរផលិតផល ទំនិញគ្រប់ប្រភេទ-ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

